# កិច្ចសំភាសន៍របស់អ៊ុំស្រីឈ្មោះ នូ វ៉ារី

**កៈ អ្នកសំភាសន៍ឈ្មោះ Matt Boyd** **ខៈ អ្នកដែលត្រូវសំភាសន៍ឈ្មោះ នូ វ៉ារី**

កៈ Ok អញ្ចឹងខ្ញុំឈ្មោះ Matt Boyd ហើយអ្នកមីងឈ្មោះអ្វីដែរ?

ខៈ ខ្ញុំឈ្មោះនូ វ៉ារី។

កៈ អញ្ចឹងថ្ងៃនេះគឺជាថ្ងៃទីដប់ពីរ ខែពីរ ឆ្នាំពីរពាន់ដប់ប្រាំមួយ ហើយឥឡូវយើងនៅ Service Center នៅភ្នំពេញ។ ហើយការសម្ភាវមួយនេះគឺសម្រាប់ Project របស់ BYU ចង់អភិរក្សពង្ស ប្រវត្តិខ្មែរ ឲ្យធ្វើឲ្យក្រុមគ្រួសារខ្មែរកាន់តែជិតស្និទ្ធ។ ហើយអញ្ចឹង អ្នកមីងអនុញ្ញាតឲ្យខ្ញុំ post ការសម្ភាសមួយហ្នឹងតាម website របស់ BYU បានទេ?

ខៈ ចាំ បាន!

កៈ Ok អញ្ចឹងឈ្មោះពិតប្រាកដ ឈ្មោះពេញរបស់អ្នកមីង ឈ្មោះអ្វីដែរ?

ខៈ តាមរបៀបខ្មែរគឺ នូ វ៉ារី។ នាមត្រកូល នូ ហើយឈ្មោះ វ៉ារី។ បើជាភាសាអង់គ្លេស ឬក៏បរទេស វ៉ារី នូ។ ចាំ។

កៈ ហើយអ្នកមីងដឹងពីថ្ងៃខែកំណើត?

ខៈ ចាំ ខ្ញុំកើតនៅថ្ងៃទីប្រាំបួន ខែ April ឆ្នាំមួយពាន់ប្រាំបួនរយហាសិបប្រាំ។

កៈ អញ្ចឹងអាយុប៉ុន្មានឥឡូវ?

ខៈ ឥឡូវហុកសិបមួយឆ្នាំហើយ។

កៈ ហើយស្រុកកំណើតរបស់អ្នកមីងនៅកន្លែងណាដែរ?

ខៈ ខ្ញុំកើតនៅខេត្តបាត់ដំបង។

កៈ នៅទីរួមខេត្ត?

ខ៖ ចាំ នៅក្នុងភូមិ— នៅទីក្រុងបាត់ដំបង ភូមិបឹងឈូក ឃុំស្វាយពោធិ៍ ស្រុកសង្កែ ខេត្តបាត់ដំបង នៅសម័យហ្នឹង។

ក៖ អ្នកមីងចាំច្បាស់។ ហើយឈ្មោះម៉ាក់ប៉ា គាត់ឈ្មោះអ្វីដែរ?

ខ៖ លោកប៉ារបស់ខ្ញុំគាត់ឈ្មោះ នូ ឆាវ។ ចាំ ហើយឥឡូវនេះគាត់អាយុប៉ែតសិបប្រាំឆ្នាំហើយ។

ក៖ Oh គាត់នៅរស់?

ខ៖ ចាំ គាត់នៅរស់។ ប៉ុន្តែម៉ាក់របស់ខ្ញុំ គាត់ឈ្មោះ លេច ប្រកប។ ចាំ ប៉ុន្តែគាត់បានស្លាប់ចោលខ្ញុំតាំងពីឆ្នាំមួយពាន់ប្រាំបួនរយហុកសិបប្រាំបួន។ តាំងពីខ្ញុំនៅអាយុដប់បួនឆ្នាំ។ ចាំ ហើយប្អូនស្រីរបស់ខ្ញុំនៅតូចនៅឡើយ នៅមឹមដោះនៅឡើយ។ ចាំ គាត់មានជំងឺលើសឈាម ហើយគាត់ដាច់សរសៃឈាម។ អញ្ចឹងគាត់ស្លាប់តាំងពីអាយុសាមសិបប្រាំឆ្នាំ។ ចាំ ហើយនិងលោកប៉ារបស់ខ្ញុំ គាត់នៅពោះម៉ាយរហូតមកដល់ឥឡូវនេះ គាត់អត់យកប្រពន្ធទៀតទេ។

ក៖ អញ្ចឹង?

ខ៖ ចាំ។

ក៖ អញ្ចឹង សម្រាប់តាយាយរបស់អ្នកមីង អ្នកមីងចាំឈ្មោះរបស់គាត់ទេ?

ខ៖ ចាំ ខ្ញុំមានតាយាយខាងម៉ាក់ លោកតារបស់ខ្ញុំខាងម៉ាក់ឈ្មោះ លោកតា លេច យុទ្ធ។ ប៉ុន្តែគាត់ស្លាប់យូរហើយ តាំងពីជំនាន់ស្តេចម៉្លេះ ជំនាន់ស្តេចសីហនុ។ ចាំ គាត់ក្មេង ស្លាប់ក្នុងវ័យក្មេងដែរ។ ចាំ គាត់ជាគ្រូបង្រៀន។

ក៖ គាត់បង្រៀនអី?

ខ៖ គាត់ជាគ្រូបង្រៀន គាត់ចេះភាសាខ្មែរ ភាសាថៃ ភាសាបារាំង។ ចាំ ហើយជីដូនរបស់ខ្ញុំគាត់ឈ្មោះ អិត មុច។ ចាំ គាត់ជា— គាត់អត់មានការងារធ្វើ ប៉ុន្តែគាត់ជាអ្នកលក់។ គាត់ធ្វើអាហារ គាត់ធ្វើតាបែ គាត់ធ្វើមានណែម លក់ដើម្បីចិញ្ចឹមកូននៅពេលដែលប្តីគាត់ស្លាប់។ ចាំ ហើយកូនរបស់គាត់មានតែពីរនាក់ទេ គឺម៉ាក់របស់ខ្ញុំ និងអ៊ំស្រីរបស់ខ្ញុំម្នាក់ឈ្មោះ លេច ម៉ាលី។ ចាំ ប៉ុន្តែឥឡូវអ៊ំស្រីហ្នឹងស្លាប់ដែរ។ ចាំ ហើយនិងខ្ញុំមានលោកយាយលោកតាខាងប៉ា លោកយាយលោកតាខាងប៉ារបស់ខ្ញុំគាត់ស្លាប់អស់ហើយ លោកតាឈ្មោះ នូ សួម។ លោកតា នូ សួម គាត់

ជាកសិករ ហើយគាត់ នៅពេលដែលគាត់មានវ័យចំណាស់គាត់បួសជាលោកសង្ឃគាត់ទៅធ្វើជាលោកសង្ឃ។ ចាំ ហើយគាត់បានស្លាប់នៅពេលដែលគាត់ឈប់ធ្វើលោកសង្ឃហើយ។ ចាំគាត់ស្លាប់តាំងពីឆ្នាំ ប្រហែលមួយពាន់ប្រាំបួនរយចិតសិបពីរ ប្រហែល។ ចាំ ហើយនិងជីដូនខាងប៉ារបស់ខ្ញុំឈ្មោះ លោកយាយ ខ្មៅ គូ។ ចាំគាត់ជាកសិករដែរ។ ហើយលោកយាយរបស់ខ្ញុំខ្លាំង គាត់ពូកែម៉ង។ គាត់អាចធ្វើកិច្ចការបានទាំងអស់ គាត់ចេះភ្ជួរស្រែគាត់ចេះដាំដំណាំ ហើយគាត់ចេះធ្វើមាសទៀត គាត់ធ្វើជាងមាស។ ចាំគាត់ចេះច្រើនហើយដោយសារការជាងមាសរបស់គាត់ដែរធ្វើឲ្យគាត់ខូចភ្នែក ឆាប់ខូចភ្នែក។ ប៉ុន្តែគាត់បានស្លាប់ហើយនៅឆ្នាំមួយពាន់ប្រាំបួនរយ— ដូចប៉ែតសិបបួន ខ្ញុំអត់ច្បាស់។

ក៖ ហើយតាយាយទូត ចាំឈ្មោះរបស់គាត់ទេ?

ខ៖ ចាំ តាយាយទូតខាងម៉ាក់របស់ខ្ញុំ [Pauses] ខ្ញុំអត់ចាំខាងម៉ាក់ដោយសារ ខ្ញុំបាត់ព័ត៌មានដោយសារខ្ញុំអត់មាន— បាត់ម្តាយ ហើយជីដូនរបស់ខ្ញុំគាត់អត់ដឹង។ តែបើតាយាយខាងប៉ាខ្ញុំចាំ ឪពុករបស់តាខ្ញុំគាត់ឈ្មោះលោកតាចែត— នូ ចែត។ ចាំ គាត់ស្លាប់អស់ហើយ ហើយលោកយាយ ខ្ញុំភ្លេច ចាំ។

ក៖ ខ្ញុំសួរពីជីវិតអ្នកមីងវិញ។ អញ្ចឹងអ្នកមីងធំឡើងនៅខេត្តបាត់ដំបង?

ខ៖ ខ្ញុំធំឡើងនៅខេត្តបាត់ដំបង។ ខ្ញុំរៀន ខ្ញុំបានសិក្សានៅក្នុងខេត្តបាត់ដំបង។ ហើយខ្ញុំកំព្រាម្តាយករនៅខេត្តបាត់ដំបង។ ហើយនៅពេលដែលខ្ញុំអត់ពីម្តាយទៅ ខ្ញុំនៅតែមានជីដូនរបស់ខ្ញុំជាអ្នកចិញ្ចឹមខ្ញុំជាមួយនិងប៉ារបស់ខ្ញុំ។ ហើយយើងមានបងប្អូនប្រាំនាក់— មានប្រាំមួយនាក់។ ចាំ ប្អូនទីពីរឈ្មោះ នូ សីនី ប្អូនទីបីឈ្មោះ នូ ឆារី ប្អូនទីបួនឈ្មោះ នូ ឆារីវង្ស ប្អូនទីប្រាំឈ្មោះ នូ ឆាករិឌី ប្អូនទីប្រាំមួយ នូ រ៉ារី។ ប៉ុន្តែទាំងប្រាំមួយនាក់និងរួមទាំងខ្ញុំហ្នឹង ឥឡូវស្លាប់អស់ពីរនាក់ នៅសល់តែបួននាក់ទេ។ នៅសល់តែខ្ញុំ ហើយនិងប្អូនស្រីពៅរបស់ខ្ញុំ ហើយប្អូនប្រុសពីរនាក់។ ចាំ ប្អូនប្រុសបន្ទាប់របស់ខ្ញុំ នូរ សីនី បានបាត់ខ្លួនតាំងពីសម័យប៉ុលពត។ ចាំ គាត់បានរត់ចេញទៅប្រទេសថៃ ប៉ុន្តែប្រហែលជាគេសម្លាប់គាត់ចោលហើយ បាត់ឈឹងរហូតមក។ ចាំ។

ក៖ អូ អត់ដែលបានឮពីគាត់?

ខ៖ អត់ដែលបានឮអ្វីសោះ អញ្ចឹងបានន័យថាគាត់ស្លាប់ហើយ។ ចាំ ហើយសម្រាប់ខ្ញុំ ខ្ញុំបានសិក្សានៅបាត់ដំបង ខ្ញុំបានបញ្ចប់ថ្នាក់វិទ្យាល័យនៅបាត់ដំបងនេះ នៅឆ្នាំមួយពាន់ប្រាំបួនរយចិតសិបបួន។ ហើយខ្ញុំបន្តការសិក្សា ខ្ញុំឡើងមកភ្នំពេញមក បន្តការសិក្សានៅមហាវិទ្យាល័យ

ច្បាប់ និងមហាវិទ្យាល័យអក្សរសាស្ត្រ។ ចាំ ប៉ុន្តែជាអកុសល ប៉ុលពតបានមកដល់ឆ្នាំមួយពាន់ប្រាំបួនរយចិតសិបប្រាំ ដូច្នេះពួកគេបានជម្លៀសខ្ញុំចេញពីទីក្រុងភ្នំពេញទៅដល់ខេត្តកំពង់ធំ។ ហើយយើងបានធ្វើជាទាសករ។ កាលហ្នឹង ខ្ញុំនៅពេញកម្លាំងយុវវ័យ អញ្ចឹងខ្ញុំក្លាយទៅជាគេហៅថាកងចល័ត។ កងចល័តហ្នឹង បានន័យថាជាក្រុមយុវជនដែលមានកម្លាំងពេញដើម្បីធ្វើការនៅសមរភូមិមុខ។ សមរភូមិមុខន័យថាទៅធ្វើជាពលករ ទៅកាប់ដី ទៅរែកដី ទៅធ្វើអ្វីសព្វបែបយ៉ាងនៅខាងមុខ។ អត់ដែលបាននៅភូមិ អត់ដែលបាននៅផ្ទះទេ យើងអត់មានផ្ទះទេ។ ហើយជីវិតខ្ញុំរស់នៅក្នុងជំរុំកងចល័តរហូត។ ហើយនិយាយពីសម័យប៉ុលពត គឺខ្ញុំជួបនិងការវេទនាខ្លាំងមែនទែន។ ខ្ញុំត្រូវបានគេធ្វើបាប ហើយពីព្រោះយើងចេញពី— គេគិតថាយើងជាអ្នកមានចេញពីទីក្រុងភ្នំពេញ។ អញ្ចឹងពួកប៉ុលពតអត់ចូលចិត្តអ្នកទីក្រុង អញ្ចឹងគេធ្វើបាបយើង។ គេអត់ដែលឲ្យសម្លៀកបំពាក់យើងអី។ អញ្ចឹងខ្ញុំមានតែខោអាវចាស់ៗ ពាក់ហើយប៉ះល្ហែកហើយប៉ះ— អ៊ែលឌើរយល់? ប៉ះពេញទាំងអស់។ ចាំ ហើយយើងទៅធ្វើការហត់រាល់ថ្ងៃ ហើយគេឲ្យយើងញ៉ាំតិចបំផុត។ អោយញ៉ាំបបរ បបរដែលរាវ។ បបរហ្នឹង គេដាំមួយខ្ទះធំហ្នឹង មួយខ្ទះហ្នឹង ទឹកមួយខ្ទះពេញហ្នឹង ដាក់អង្ករតែបីកំប៉ុងទេ។ អ៊ែលឌើរគិតមើលថារាវខ្លាំងមែនទែន។ អញ្ចឹងយើងខ្ញុំរស់ ខ្ញុំស្គមមែនទែនសម័យនោះ។ ប៉ុន្តែខ្ញុំបានព្យាយាមធ្វើការងារគ្រប់បែបយ៉ាងដែលគេឲ្យយើងធ្វើបាន គ្រប់បែបយ៉ាងទាំងអស់។ អញ្ចឹងគេអត់សម្លាប់ខ្ញុំទេ។ ចាំ ហើយអ្នកជិតខាងត្រូវបានសម្លាប់ចោលអស់ ភាគច្រើនដោយសារតែនាក់ដែលចេញពីភ្នំពេញទៅ។ ចាំ ហើយឪពុកមានិងម្ដាយមីងខ្ញុំ ដើរចេញពីភ្នំពេញ គាត់នៅក្នុងភូមិគាត់តែធ្វើការនៅក្នុងភូមិ។ ប៉ុន្តែ នៅក្នុងសម័យហ្នឹង ខ្ញុំបានបាត់បង់បងប្អូនបងប្រុសជីដូនមួយម្នាក់ ដែលចេញពីភ្នំពេញទៅជាមួយគ្នាបានស្លាប់ដែរ ហើយនិងប្អូនស្រីជីដូនមួយម្នាក់ទៀតដែលស្លាប់ដែរ ដើយសារតែគាត់រាករូស ហើយឃ្លានខ្លាំងពេក។ អញ្ចឹងហើយនៅពេលដែលគេធ្វើបាបខ្ញុំខ្លាំងជាងគេនៅពេលដែលឆែកនៅក្នុង បង្វេចរបស់ខ្ញុំនេះខ្ញុំលាក់ certificate សញ្ញាប័ត្រសិក្សារបស់ខ្ញុំដែលខ្ញុំប្រឡងជាប់ សិស្សវិទ្យាល័យហើយនឹង card របស់ខ្ញុំនៅមហាវិទ្យាល័យ។ គេរកឃើញ គេថា « អូ! នេះជាកូនអ្នកមាន! » អញ្ចឹង មេកងចល័តមេកងរបស់ខ្ញុំ ចិត្តអាក្រក់ គេបាននាំខ្ញុំទៅដើម្បីឲ្យ គេធ្វើការសម្ភាសនៅមេសន្តិសុខ។ អញ្ចឹងគេយកខ្ញុំពីកន្លែងទៅពីជំរុំរស់នៅ ឆ្លងទៅកន្លែងមួយទៅកន្លែងមួយដើម្បីធ្វើការសួរ។ ចាំ អញ្ចឹងខ្ញុំទៅជួបនិងមេកងសន្តិសុខ ហើយគាត់ក៏គួរឲ្យខ្លាចដោយសារគាត់ជាអ្នកមានអំណាចខ្លាំង ហើយត្រូវកត់— អ្នកណាដែលជួបគាត់ គឺត្រូវតែស្លាប់។ ហើយនៅពេលដែលមុនដែលខ្ញុំចេញទៅ ខ្ញុំបានផ្ដាំអ្នកជិតខាងថាបើសិនជាអត់ឃើញខ្ញុំត្រឡប់មកវិញទេ សូមយកខោអាវខ្ញុំទៅឲ្យបងប្អូនខ្ញុំទៅ បានន័យថាខ្ញុំស្លាប់ហើយ។ ចាំ ប៉ុន្តែនៅពេលដែលខ្ញុំទៅជួបមេកងសន្តិសុខ ប្រធានសន្តិសុខហ្នឹង— គេបានសម្ភាសខ្ញុំ ដូច

ការសម្អាសគេអញ្ចឹង សួរថា « អ្នកឯងឈ្មោះអ្វី ធ្វើអ្វីៗ? » ខ្ញុំបានប្រាប់គេថា « ខ្ញុំឈ្មោះ នូ វ៉ារី ឪពុកខ្ញុំជាកម្មករធ្វើផ្លូវក្រីក្រ ហើយខ្ញុំអាច— ហើយខ្ញុំអត់មានម្ដាយទេ ខ្ញុំរស់នៅដោយសារជីដូនជាអ្នកចិញ្ចឹម។ ខ្ញុំពិបាកណាស់ គ្រួសារខ្ញុំក្រីក្រណាស់។ » ខ្ញុំនិយាយប្រាប់គេអញ្ចឹង។ « ហើយខ្ញុំអាចទៅរៀននៅភ្នំពេញបាន ដូចអ្នកឯងឃើញសញ្ញាបត្រ័ខ្ញុំហ្នឹង ដោយសារខ្ញុំមានឪពុកធំ— អ៊ំខ្ញុំ អ៊ំរបស់ខ្ញុំ គាត់អត់មានកូន។ អញ្ចឹងគាត់ចិញ្ចឹមខ្ញុំគាត់ឲ្យខ្ញុំទៅរៀន។ » បានគេថា « អូ! អញ្ចឹងអត់អីៗ។ » ចាំ « អញ្ចឹងអ្នកឯងត្រូវតែធ្វើការដើម្បីបម្រើបក្ស ដើម្បីបម្រើប្រទេសជាតិ អ្នកឯងត្រូវបម្រើអង្គការ។ កុំក្បត់អង្គការ។ » អញ្ចឹងអត់អីទេ។ » អញ្ចឹងគាត់ និយាយចុះនិយាយឡើងគាត់ជា Professor គាត់ជា Teacher ដែរ។ អញ្ចឹងនិយាយចុះនិយាយឡើងទៅគាត់ហាក់ដូចជាមានអារម្មណ៍ថាគ្រូនិងសិស្សនិយាយគ្នា គាត់អាណិតខ្ញុំ។ គាត់ឲ្យខ្ញុំត្រឡប់មកវិញ។ ខ្ញុំបានចាប់ផ្ដើមរស់ម្ដងទៀត។ អញ្ចឹងនេះជាជីវិតសម័យប៉ុលពត។ ហើយខ្ញុំបានជួបនិងប្ដីរបស់ខ្ញុំ— ប្ដីរបស់ខ្ញុំជាអ្នកស្រុកនៅស្វោងហ្នឹងដែរ។ គាត់កើតនៅស្រុកស្វោងហ្នឹងដែរ ប៉ុន្តែគាត់ឲ្យទៅរៀននៅភ្នំពេញដែរ។ ហើយគាត់ទៅធ្វើទាហាន Marine ទាហានជើងទឹក។ ប៉ុន្តែនៅពេលដែលប៉ុលពតចប់គាត់វិលត្រឡប់មកស្រុកវិញ។ ហើយពេលគាត់ឃើញខ្ញុំ គាត់ក៏ចង់រៀបការជាមួយខ្ញុំ។ ប៉ុន្តែខ្ញុំអត់ចង់បានទេ ដោយសារខ្ញុំអត់ចង់បានប្ដី ព្រោះខ្ញុំចង់ត្រឡប់មកផ្ទះវិញ។ ប៉ុន្តែនៅពេលដែលគាត់ព្យាយាម— នៅសម័យហ្នឹងយើងឃ្លានមែនទែន។ យើងញ៉ាំអត់គ្រប់ទេ ញ៉ាំតែបបររាវ ហើយស្គម។ អញ្ចឹងគាត់ ប្ដីរបស់ខ្ញុំកាលហ្នឹង គេឲ្យគាត់មានរទេះគោ ហើយគាត់ទៅដឹកសេដ្ឋកិច្ច ទៅដឹកស្បៀង ដឹកអង្ករ ដឹកអីពីកន្លែងឃ្លាំងមកកន្លែងផ្ទះបាយ។ អញ្ចឹងគាត់មានអង្ករ គាត់លួចអង្ករដើម្បីផ្ញើខ្ញុំ។ គាត់ធ្វើដើម្បីឲ្យខ្ញុំស្រឡាញ់គាត់។ ចាំ អញ្ចឹងនៅពេលដែលខ្ញុំបានហូប ហើយគាត់មានលួចត្រីងៀតដើម្បីផ្ញើមកឲ្យខ្ញុំ។ ចាំ ជួនកាលគាត់មានស្ករផ្ញើមកឲ្យខ្ញុំ មានអំបិលផ្ញើឲ្យខ្ញុំ អញ្ចឹងអ្វីដែលខ្ញុំអត់មានអីសោះ។ ខ្ញុំចាប់ផ្ដើមទន់ចិត្តដោយសារខ្ញុំគិតថាខ្ញុំអាចរស់បានហើយ ខ្ញុំក៏សម្រេចចិត្តរៀបការជាមួយគាត់។ ហើយរៀបការ ការរៀបការរបស់ខ្ញុំ យើងរៀបការមិនមែនតាមតែពីរនាក់ទេ គឺមានចិតសិបប្រាំបី pair ចិតសិបប្រាំបីគូ។ ក្នុងពីធីការរៀបការមួយពេលហ្នឹង សម័យហ្នឹង មានចិតសិបប្រាំបី couples ។ អញ្ចឹងយើងរៀបការរួមគ្នា ហើយគេឲ្យ គេចែកសំពត់អាវខ្មៅឲ្យយើង ពណ៌ខ្មៅ ហើយកន្សែងបង់ក កន្សែងឲ្យយើងរុំក។ ហ្នឹងហើយ ហើយអត់មានស្បែកជើងទេ។ ដូច្នេះប្ដីរបស់ខ្ញុំស្រឡាញ់ខ្ញុំពេក គាត់បានទៅលួចស្បែកជើងពីកន្លែងពួកកងទ័ព។ ហើយយកមកឲ្យខ្ញុំពាក់ អញ្ចឹងខ្ញុំបានមានសម្លៀកបំពាក់មានស្បែកជើងដើម្បីរៀបការ។ ចាំ ហើយនៅពេលរៀបការហ្នឹង គេមានពិធីជប់លៀង។ អញ្ចឹងយើងត្រូវមានស្លាបព្រាដាក់ក្នុងកំប៉ោ។ បើមិនចឹងយើងអត់មានអីញ៉ាំអី។ ហ្នឹងគឺជា— អញ្ចឹងពេលរៀបការហ្នឹងគឺជាពេលដែលយើងបានញ៉ាំឆ្អាញ់ជាងគេ

នៅក្នុងពេលហ្នឹងគេមានកាប់សាច់ជ្រូក ធ្វើម្ហូបឲ្យយើងញ៉ាំ។ ហ្នឹងហើយ អញ្ចឹងខ្ញុំរៀបការនៅ
ឆ្នាំ ជិតមួយពាន់ប្រាំបួនរយចិតសិបប្រាំបី។ ចា៎ ហើយគេបានឲ្យខ្ញុំទៅធ្វើការនៅផ្សេង ប្ដីខ្ញុំធ្វើ
ការនៅផ្សេង។ ចា៎ ដល់ឆ្នាំចិតសិបប្រាំបួនវៀតណាមចូលមក ហើយខ្ញុំមានទំងន់ហើយ។ ឆ្នាំ
ចិតសិបប្រាំបួន កងទ័ពវៀតណាមចាប់ផ្ដើមចូលមក អញ្ចឹងខ្ញុំបាន— យើងត្រូវបានរំដោះ
ហើយយើងបានក្លាយទៅជាប្រជាជនដែលឈប់ធ្វើទាសករឲ្យពួកហ្នឹងទៀតហើយ។ ហើយខ្ញុំ
ក៏បានកូនមួយនៅក្នុងស្រុកស្មោងហ្នឹង។ ខ្ញុំកើតបានកូនស្រីមួយនៅក្នុងឆ្នាំមួយពាន់ប្រាំបួនរយ
ចិតសិបប្រាំបួន ខែប្រាំបី។ ចា៎ ហើយបន្ទាប់មកទៀត ឪពុករបស់ខ្ញុំគាត់បានដំណឹងថា គាត់ឮ
ប្រហែលជាមានគេប្រាប់ថាខ្ញុំ— មានកូនស្រីដែលបាត់ខ្លួនហ្នឹងរស់នៅស្រុកស្មោង។ អញ្ចឹង
គាត់បានព្យាយាមជិះទូកតាមស្ទឹងទៅ ដើម្បីទៅដល់ឆ្លងសៀមរាប ហើយឆ្លងទៅដល់កំពង់ធំ
ស្មោងហ្នឹងដើម្បីជួបខ្ញុំ។ ហើយយើងបានជួប ខ្ញុំបានជួបប៉ាខ្ញុំជាលើកទីមួយក្រោយពីសម័យ
ប៉ុលពត។ ហើយខ្ញុំរំភើបណាស់ ហើយខ្ញុំស្ទើរតែអត់ស្គាល់គាត់ ដោយសារខ្ញុំភ្លេចអស់នៅពេល
សម័យប៉ុលពតហ្នឹង។ យើង— ខ្ញុំមានអារម្មណ៍ថាខ្ញុំបាត់អស់ពីក្នុងខួរក្បាលខ្ញុំ តាំងពីចំណេះ
ដឹង តាំងពី បងប្អូនមិត្តភក្ដិមុខម៉េចហ្នឹង គឺខ្ញុំសឹងភ្លេចអស់ហើយ។ ប៉ុន្តែនៅពេលដែលខ្ញុំជួបប៉ា
ខ្ញុំវិញ ខ្ញុំស្គាល់ភ្លាម ខ្ញុំឱបគាត់ភ្លាម។ ចា៎ គាត់ចង់នាំខ្ញុំត្រឡប់មកផ្ទះវិញ ប៉ុន្តែខ្ញុំមានកូនតូច
អញ្ចឹងគាត់ឲ្យខ្ញុំនៅស្រុកស្មោងសិន ហើយគាត់ត្រឡប់មកវិញ។ ខ្ញុំចាប់ផ្ដើមរស់នៅស្រុក
ស្មោងជាមួយប្ដី ហើយប្ដីរបស់ខ្ញុំគាត់រកស៊ីឡើងត្នោត ចា៎ ដើម្បីធ្វើស្ករ។ គាត់ជាអ្នកឡើងទៅ ខ្ញុំ
ជាអ្នកកូរ កូរស្ករ។ ចា៎ ហើយផុតពីហ្នឹង ខ្ញុំរកស៊ីលក់ចាប់ហួយ ដាក់នៅលើកង់។ ហើយខ្ញុំជិះ
កង់ដឹកស្ករអំបិលប៊ីចេងអីៗ ហ្នឹង ទៅឆ្ងាយជិះកង់ទៅលក់នៅឆ្ងាយ ហើយត្រឡប់មកវិញមាន
អង្ករមកវិញ។ មិនមែនលក់ជាលុយទេ និងលក់ជាអង្ករឬក៏ជាស្រូវ។

ក៖ Ah ជាលុយ។

ខ៖ ចា៎ ហើយពេលខ្លះ— ហើយខ្ញុំមានកូនតូចទៀត អញ្ចឹងកូនខ្ញុំកើតហើយប៉ុន្តែឪពុកក្មេក
របស់ខ្ញុំ គាត់បានមើលកូនរបស់ខ្ញុំ។ ខ្ញុំភ្លេចប្រាប់ថាឪពុកក្មេករបស់ខ្ញុំគាត់នៅរស់សម័យប៉ុល
ពតហ្នឹង គាត់ឈ្មោះ គឹរ អឿល។ ហើយឥឡូវនេះគាត់ស្លាប់ហើយ ហើយម៉ាក់ក្មេករបស់ខ្ញុំ
ឈ្មោះ ថ្លាង គីមអាន។ គាត់ស្លាប់សម័យប៉ុលពត អញ្ចឹងខ្ញុំអត់បានស្គាល់ម្ដាយក្មេកទេ ខ្ញុំស្គាល់
តែឪពុកក្មេកដែលចិញ្ចឹម— ខ្ញុំបានចិញ្ចឹមគាត់។ ដោយសារគាត់អត់មានធ្វើអីកើត ហើយប្ដីខ្ញុំ
ត្រូវចិញ្ចឹមគាត់ ពួកយើងចិញ្ចឹមគាត់។ ហើយគាត់មើលកូនឲ្យយើង។ ចា៎អញ្ចឹងខ្ញុំបានធ្វើរកស៊ីអី
ហ្នឹងផង ហើយជូនកាលខ្ញុំទៅម៉ោងព្រឹក ល្ងាចឡើងបានខ្ញុំមកវិញ អញ្ចឹងកូនរបស់ខ្ញុំបៅទឹក
បបរ។ ហើយនៅពេលដែលខ្ញុំឡើងទៅឆ្ងាយអញ្ចឹងទៅលក់ទាំងថ្ងៃ ដោះខ្ញុំដែលកូនត្រូវបៅ

នោះវាច្រើន ទឹកដោះច្រើន។ អញ្ចឹងខ្ញុំឲ្យកូនក្មេងដែលអត់មានទឹកដោះបៅឲ្យបៅជំនួសទៅ។
ចា៎ ខ្ញុំបានចិញ្ចឹមក្មេងផ្សេងៗច្រើនទៀត។ ចា៎ ហើយបន្ទាប់ពីលក់ដូរហ្នឹងមក វាមិនអាចចិញ្ចឹម
ខ្លួនរស់ទេ ឬក្រុមគ្រួសារបាន។ អញ្ចឹងខ្ញុំចាប់ផ្ដើមធ្វើគ្រូ ចូលធ្វើគ្រូបង្រៀននៅស្រុកស្ទោង។
នៅឆ្នាំមួយពាន់ប្រាំបួនរយប៉ែតសិបមួយខ្ញុំធ្វើគ្រូបានពីរឆ្នាំ។ រួចហើយបានខ្ញុំត្រឡប់មកបាត់
ដំបងវិញនៅក្នុងឆ្នាំមួយពាន់ប្រាំបួនរយប៉ែតសិបបួន នៅពេលដែលកូនរបស់ខ្ញុំបានអាយុ
ប្រហែលជាបីឆ្នាំជាងទៅបួនឆ្នាំ— អូ មើល! ប្រាំឆ្នាំ។ ប៉ែតសិបបីយើងត្រឡប់មកវិញ។ ចា៎
ហើយមកដល់បាត់ដំបងវិញ ខ្ញុំមកនៅជាមួយនឹងឪពុកនិងជីដូនរបស់ខ្ញុំនិងប្អូនៗរបស់ខ្ញុំវិញ។
ហើយនៅឆ្នាំមួយពាន់ប្រាំបួនរយប៉ែតសិបបួនខ្ញុំបានចាប់ផ្ដើមចូលធ្វើការនៅមន្ទីរឧស្សាហកម្ម
ខេត្តបាត់ដំបង។ ចា៎ ខ្ញុំធ្វើការខាងការងារទទួលសិប្បកម្មហើយនិងការកើតរោងចក្រនិងស្អីៗ
ហ្នឹង។ ចា៎ហើយដល់ឆ្នាំ— ហើយយើងមានប្រាក់ខែតិចមែនទែន។ ប្រាក់ខែហ្នឹងជាអង្ករទៀត។
ហើយមិនអាចចិញ្ចឹមកូនរស់ទេ។ អញ្ចឹងពេលធ្វើការខ្ញុំឱប ខ្ញុំចងកុមារនិងកង់ ហើយដាក់កូនពី
មុខទៅ ហើយទៅធ្វើការ ហើយប្ដីរបស់ខ្ញុំគាត់នៅផ្ទះធ្វើស្រែ។ ហើយធ្វើការបណ្ដើរ ខ្ញុំសរសេរ
សៀវភៅរឿង សរសេរសៀវភៅប្រលោមលោក។ សម័យហ្នឹងគឺយើងអត់មានបោះពុម្ពអីទេ
មានតែសរសេរ។ ខ្ញុំសរសេររាល់ថ្ងៃ ហើយខ្ញុំសរសេរហើយចប់មួយរឿងខ្ញុំលក់ឲ្យគេ ចប់មួយ
រឿងខ្ញុំលក់ឲ្យគេ។ ខ្ញុំសរសេរបានបួនប្រាំរឿង លក់ឲ្យគេប៉ុតែមិនបានថ្លៃទេ បានថោក។ ហើយ
អ្នកដែលទិញទៅហ្នឹង គាត់យកសៀវភៅហ្នឹងទៅជួលឲ្យគេចម្លង។ ដូចជាបោះពុម្ពចឹងណា៎?
ចា៎ ចម្លងច្រើនទៅ ហើយគេជួលដើម្បីអាន។ ចា៎ ហើយយប់ឡើងខ្ញុំធ្វើចាក់កន្សែង ខ្ញុំគូររូប
ដើម្បីលក់ឲ្យកូនក្មេងនៅសាលារៀន ហើយយើងបានដាំដំណាំនៅជិតផ្ទះដើម្បីលក់។ ហើយ
ពេលល្ងាចឡើង ខ្ញុំចងបន្លែដើម្បីលក់។ ហើយយប់ឡើងម៉ោងពីរ ខ្ញុំចាប់ផ្ដើមក្រោក ពីម៉ោងពីរ
ដើម្បីធ្វើដំណើរទៅទូលអីវ៉ាន់ធូន់បន្លែហ្នឹងទៅលក់ ហើយចំការភ្លៀងទៅរអិលដួលក៏មាន
វេទនាណាស់។ ហើយសម័យនោះប្ដីខ្ញុំចាប់ផ្ដើមផឹកស្រា គាត់ចាប់ផ្ដើមមានមិត្តភក្តិហើយគាត់
ចាប់ផ្ដើមញាំស្រា ហើយធ្វើបាបគ្រួសារខ្លាំងមែនទែន។ អញ្ចឹងបន្ទាប់ពីធ្វើគ្រូហើយធ្វើនៅ
ឧស្សាហកម្មហើយ នៅឆ្នាំមួយពាន់ប្រាំបួនរយកៅសិបពីរ មាតុភូមិនិវត្តន៍ជនភៀសខ្លួនខ្មែរ
ដែលទៅប្រទេសថៃបានត្រឡប់មកវិញ។ អញ្ចឹងខ្ញុំចាប់ផ្ដើមធ្វើការជាមួយ កាកបាទក្រហម។
បានបីឆ្នាំដើម្បីទទួលពួកអ្នកភៀសខ្លួនហ្នឹង ខ្ញុំធ្វើការនៅហ្នឹង ធ្វើជាកើតមានជា admin ដំបូងជា
ចុងភៅ ជាអ្នកដាំបាយគេ។ ប៉ុន្តែនៅពេលគេធ្វើការ ខ្ញុំឧស្សាហ៍ជាងគេ។ អ្នកដទៃទៀតគេចិត
បន្លែ គេចិតអីៗហៅគេស្លហើយគេអង្គុយលេង។ សម្រាប់ខ្ញុំ ខ្ញុំធ្វើហើយខ្ញុំលាងសំអាតអីៗ ចឹង
ទៅ ប្រធានមណ្ឌលគាត់ឃើញខ្ញុំឧស្សាហ៍ជាងគេ គាត់យកប្រវត្តិរូបខ្ញុំមកមើល គាត់ឃើញថាខ្ញុំ
រៀនបានច្រើន។ អញ្ចឹងគាត់ហៅខ្ញុំឲ្យទៅធ្វើនៅ admin ខាង statistics ។ ហើយអញ្ចឹងខ្ញុំបាន

ធ្វើការខ្ញុំសហការជាមួយ UNHCO ជាមួយ welfare program ជាមួយនឹងអង្គការផ្សេងៗ ក្នុងការជួយដល់គាំទ្រ ជួយដល់ពួកជនភៀសខ្លួនដើម្បីឲ្យពួកគេមានស្បៀងអាហារ ហើយគេមាន coupon ដើម្បីបានអាហារាល់ខែ ហើយនិងគេមានជ្រកស្នាក់នៅ។ អញ្ចឹងខ្ញុំធ្វើការរហាត់ដល់ចប់ការងារជនភៀសខ្លួនបានខ្ញុំទៅធ្វើការនៅអង្គការមួយទៀត អង្គការខ្មែរឈ្មោះក្រុមអភិវឌ្ឍន៍ភូមិ ពីឆ្នាំមួយពាន់ប្រាំបួនរយកៅសិបបួន។ ចាំ ចាប់ផ្តើមធ្វើការនៅទីនោះ ហើយខ្ញុំចាប់ផ្តើមធ្វើការរហូតដល់ឆ្នាំ— ដល់ខ្ញុំបាន ក្នុងការធ្វើការងារហ្នឹងខ្ញុំបានទៅធ្វើការសិក្សានៅប្រទេសវៀតណាម នៅប្រទេសថៃ នៅប្រទេសឥណ្ឌា។ ចាំ យើងបានធ្វើ ខ្ញុំបានទៅច្រើនប្រទេស។ ហើយខ្ញុំបានក្លាយទៅជាអ្នកដឹកនាំរបស់អង្គការហ្នឹងដោយគេ ដោយសារយើងធ្វើបានល្អ អញ្ចឹងខ្ញុំបានក្លាយទៅជាប្រធានអង្គការ។ ប៉ុន្តែដោយសារអង្គការខ្ញុំមាន fund តិច ហើយខ្ញុំមានត្រូវឡានបុកម្តង ហើយអញ្ចឹងអត់មាន insurance ដើម្បីព្យាបាលជំងឺយើង ខ្ញុំចាប់ផ្តើម apply មកអង្គការមួយទៀត ដែលខ្ញុំធ្វើការរាល់ថ្ងៃហ្នឹង គឺអង្គការ CWS— Church World Service ។ ចាំ អញ្ចឹងខ្ញុំចាប់ផ្តើមធ្វើការងារនៅអង្គការហ្នឹង ហើយខ្ញុំចាប់ផ្តើមមាន insurance មានអី។ ហើយការងាររបស់ខ្ញុំគឺធ្វើនៅតំបន់ដែលឆ្ងាយបំផុត តំបន់ដែលអ្នកដទៃទៀតអត់ទៅដល់ ដូចនៅស្រុកសំឡូត ស្រុកសំពៅលូន ជាតំបន់ដែលអត់មានផ្លូវ។ យើងជិះទៅលើដី។ ហើយពេល—

កៈ នៅខេត្តបាត់ដំបង?

ខៈ ចាំ ហើយបើពេលភ្លៀងមកគឺដួលរហូត ដួលរហូត ហើយជាតំបន់ដែលអត់មានទឹក ហើយជាតំបន់ដែលកុមារក្រីក្រហ្នឹង អត់ដែលបានទទួល vaccination អត់ដែលបានទទួលវ៉ាក់សាំង។ អត់ដែលបានទទួលការអាហារូបត្ថម្ភ (ចំណីអាហារគ្រប់គ្រាន់) ហើយឪពុកម្តាយដាក់ចោល អីចឹង យើងធ្វើការនៅតំបន់អស់ហ្នឹង។ បើនៅសំឡូត ខ្ញុំត្រូវឆ្លងភ្នំ ជិះម៉ូតូជាងមួយរយគីឡូដើម្បីទៅដល់ទីតាំងធ្វើការហ្នឹង ឆ្លងកាត់ភ្នំ កាត់ព្រៃ ហើយពេលត្រឡប់មកវិញជួនកាលព្រលប់ៗចេញពីភូមិមកវិញ ជួនកាលមកតាមផ្លូវម្នាក់ឯង ខ្ញុំមានតែព្រះទេ។ ចាំ អញ្ចឹងពេលខ្លះខ្ញុំឃើញភ្នែកមួយគូខៀវនៅពីមុខផ្លូវរបស់ខ្ញុំ អញ្ចឹងខ្ញុំបានអធិដ្ឋានរហូត។ ហើយខ្ញុំបានភ្លេចនិយាយអំពីសេចក្តីជំនឿរបស់ខ្ញុំ។ ពីមុនខ្ញុំជាសាសនាព្រះពុទ្ធ ប៉ុន្តែនៅឆ្នាំមួយពាន់ប្រាំបួនរយប៉ែត— នៅឆ្នាំពីរពាន់បី យើងចាប់ផ្តើមមានសាសនាចក្រនៅបាត់ដំបង។ អញ្ចឹងខ្ញុំបានចូលរៀនជាមួយអ៊ែលឌើរ អ៊ែលឌើរបានទៅបង្រៀនយើង ហើយបានបង្រៀនយូរជាងគេប្តីរបស់ខ្ញុំ ពីព្រោះគាត់ផឹកស្រា។ អញ្ចឹងយើងរៀនប្រហែលប្រាំមួយខែ រហូតដល់ថ្ងៃទីសាមសិបមួយ ខែមួយ ឆ្នាំពីរពាន់បួន បានខ្ញុំ បានយើងបានជ្រមុជទឹក។ អញ្ចឹងយើងរៀនច្រើនមែនទែន ទម្រាំតែគាត់ផ្តាច់ស្រា ហើយឲ្យគាត់បានក្លាយទៅជាមនុស្សម្នាក់ថ្មី។ ហើយអ្នកដែលជ្រមុជទឹកឲ្យខ្ញុំគឺ ប្រធាន

ហៃថោវើ។ ចាំ ហើយយើងបានក្លាយទៅជាសមាជិកនៅពេលហ្នឹង ហើយបន្ទាប់មកទៀតគឺក្រុមគ្រួសាររបស់ខ្ញុំចាប់ផ្តើមជាសមាជិកបន្តបន្ទាប់គ្នា។ ហើយខ្ញុំមានក្មួយម្នាក់ឈ្មោះ អ៊ែលឌើរ អ៊ឹម គាត់បានចេញផ្សព្វផ្សាយសាសនានៅស្រុកខ្មែរយើងដែរ។ ប៉ុន្តែកូនៗខ្ញុំអត់បានចេញទេ ដោយសារគាត់ជាប់រៀន ហើយដូចគាត់ខ្លាចម៉ង។ ហើយនៅក្នុងសាសនាចក្រ ប្តីរបស់ខ្ញុំបានធ្វើធ្វើជាប្រធានសាខាតាំងពី— ដំបូងមានប្រធាន ស្តាយិន (President Sda Yin)។ ប៉ុន្តែប្រធានស្តាយិន គាត់ធ្វើការ គាត់អត់មានពេលធ្វើការដោយសារគាត់ចង់ធ្វើការនៅផ្សេងៗ អញ្ចឹងប្តីខ្ញុំជាទីប្រឹក្សាទី១ គាត់បានធ្វើការងារកិច្ចការសាខាទាំងអស់ ហើយក្រោយមកគាត់បានឡើងធ្វើជាប្រធានសាខា។ ហើយនៅឆ្នាំពីរពាន់ដប់ គាត់បានក្លាយជាប្រធានមណ្ឌលបាត់ដំបង។ ចាំ ហើយនៅក្នុងឆ្នាំពីរពាន់ដប់បី គាត់បានដោះលែង។ ចាំ ឥឡូវគាត់បម្រើជាស្មៀននៅក្នុងសាខា។ គេឲ្យគាត់ធ្វើប្រធានសាខា ប៉ុន្តែក៏អត់ចង់ធ្វើទៀត។ ហើយសម្រាប់ខ្ញុំ ដំបូងខ្ញុំជាគ្រូថ្នាក់ស្ត្រី បន្ទាប់មកទៀតខ្ញុំបានក្លាយទៅជាទីប្រឹក្សាស្ត្រី។ ហើយបន្ទាប់មកទៀត ខ្ញុំក្លាយទៅជាប្រធានស្ត្រីប្រាំពីរឆ្នាំ។ ចាំប្រាំពីរឆ្នាំ ហើយខ្ញុំបានជួយស្ត្រីជាច្រើន ដើម្បីឲ្យមានភាពរឹងមាំ។ ហើយទោះខ្ញុំបានបម្រើការងារជាច្រើន ខ្ញុំបានបម្រើ បង្រៀននៅថ្នាក់វិទ្យាស្ថានប្រាំពីរឆ្នាំដែរ។ ហើយខ្ញុំបានធ្វើការពង្សប្រវត្តិ ធ្វើកិច្ចការពង្សប្រវត្តិ។ ហើយឥឡូវខ្ញុំបានដោះលែងអស់ហើយពីស្ត្រី ខ្ញុំក្រោយមកទៀតខ្ញុំក្លាយជាស្ត្រីមណ្ឌល ទីប្រឹក្សាទីមួយនៅស្ត្រីមណ្ឌល។ ឥឡូវខ្ញុំដោះលែង ខ្ញុំបម្រើតួនាទីជាប្រធានកុមារ។ ចាំ នេះជាជីវិតរបស់ខ្ញុំ នៅក្នុងការរស់នៅហើយនិងជីវៈប្រវត្តិក្នុងសាសនាចក្រ។ ចាំៗ ហើយ ឥឡូវខ្ញុំមានចៅប្រាំពីរនាក់ហើយ។ ចាំ ហើយកូនរបស់ខ្ញុំក្លាយទៅជាសមាជិកទាំងអស់លើកលែងតែកូននៅអាមេរិកដែលគាត់អត់បាននេះ ហើយកូនម្នាក់ទៀតនៅឆ្ងាយដែលអត់បានជាសមាជិក។ ក្រៅពីហ្នឹងសមាជិកទាំងអស់ ហើយខ្ញុំអូសទាញបានជន្លងខ្ញុំពីរគ្រួសារទៀតជាសមាជិកដែរ។ អញ្ចឹងក្រុមគ្រួសាររបស់យើងជាសមាជិកច្រើនមែនទែន ជិតម្ភៃនាក់។ ចាំៗ

ក៖ Wow.

ខ៖ អញ្ចឹងខ្ញុំសង្ខេបប្រវត្តិរបស់ខ្ញុំតែប៉ុណ្ណឹង ចាំ សូមអរគុណ៕